**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**
សំណុំរឿងព្រហ្មទណ្ឌលេខ:១៧២
ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧

**តាំងនាមប្រជារាស្ត្រខ្មែរ**

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ១២ (ច)
ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៨

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ ។*

*ដោយមានសមាសភាព:*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*
២-លោកស្រី [redacted] *តំណាងអយ្យការ*
៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*ដើម្បីជំនុំជម្រះលើជនជាប់ចោទ:*

១-ឈ្មោះ:[redacted]ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ននៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted]ស) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុន មាន (ឃុំខ្លួនថ្ងៃទី **១៧ ខែ មីនា ឆ្នាំ២០១៧**)។

ត្រូវជាប់ចោទពីបទ: ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧ វេលាម៉ោង ០៨និង៣០នាទី ស្ថិតនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង កើតមានករណី អំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (យកច្រវ៉ាក់វាយក្បាលម្តាយបង្កើត) ដែលបង្កឡើងដោយឈ្មោះ:[redacted]ភេទប្រុស អាយុ ១៩ឆ្នាំ នៅភូមិកណ្តាល ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង បានយកច្រវ៉ាក់វាយទៅលើម្តាយបង្កើតឈ្មោះ[redacted]បណ្តាលឲ្យរបួសត្រង់ក្បាលបែកក្បាលហូរឈាម [redacted] ជាជនជាប់ចោទធ្លាប់ប្រើអំពើហិង្សាទៅលើម្តាយជាច្រើនលើកច្រើនសារមកហើយ។



Scanned by CamScanner

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៥៦១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៥៨៧ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៨៣៥ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា: កាលពីថ្ងៃកើតហេតុ ខ្លួនពិតជាបានទាញយកច្រវាក់វាយពីលើក្បាលម្តាយរបស់ខ្លួនឈ្មោះ[redacted]ិតប្រាកដមែន ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ានឆ្លើយថា: កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៧ វេលាម៉ោង ០៨ និង៣០នាទីព្រឹក ខ្លួនមកពីការគេនៅក្នុងភូមិជាមួយគ្នា ពេលត្រឡប់មកផ្ទះវិញខ្លួនក៏បានឈាងចូលទៅទិញផ្លែចេកមួយស្និត និងឪឡឹកមួយផ្លែមកផ្ញើកូន ពេលខ្លួនបានយកផ្លែចេក និងផ្លែឪឡឹកអោយកូនប្រុសដែលអង្គុយលើគ្រែក្រោមផ្ទះដើម្បីឲ្យវាហូប ស្រាប់តែកូនប្រុសបាននិយាយថា ឯងយកអីមកអោយអញស៊ីទៀតហើយ ឯងរឹងក្បាលណាស់ រួចខ្លួនក៏ដើរចេញបានពីរបីជំហ៊ានកូនប្រុសខ្លួន ក៏បានទាញយកច្រវ៉ាក់វាយក្បាលខ្លួនពីក្រោយដោយមិនដឹងខ្លួនបណ្តាលអោយរបេះហូរឈាម ខ្លួនក៏រត់ទៅអោយអ្នកជិតខាងជួយបញ្ជូនទៅមន្ទីរពេទ្យដេរបួសដប់ពីរថ្នេរ។

-ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ[redacted]បានឆ្លើយថា: ដំបូងឡើយម្តាយរបស់ឈ្មោះ[redacted] បានទិញផ្លែឪឡឹកមកផ្ញើកូនដើម្បីហូប ប៉ុន្តែពេលដើរចេញមកវិញ ស្រាប់តែឈ្មោះ[redacted]កច្រវ៉ាក់វាយពីលើក្បាលរបស់ឈ្មោះ[redacted]តម្តង ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted] ពីបទ ហិង្សាដោយចេតនា(មានស្ថានទម្ងន់ទោស) តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់។

-ជនជាប់ចោទឈ្មោះ[redacted]ានសំណូមពរចុងក្រោយ: ខ្លួនពុំមានសំណូមពរអ្វីឡើយ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned by CamScanner

# <u>សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:</u>

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៨៧ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted]មក តុលាការដើម្បីជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ ប្រព្រឹត្តនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្លួនពិតជាបាន យកច្រវ៉ាក់វាយទៅលើម្តាយប្រាកដមែន ។

៣-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ កូនខ្លួនពិតជាយកច្រវ៉ាក់ មកលើខ្លួនត្រូវក្បាលប្រាកដមែន ។

៤-ចម្លើយមន្ត្រីនគរបាលឈ្មោ[redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ ឈ្មោ[redacted]បានយកច្រវ៉ាក់ វាយទៅលើម្តាយប្រាកដមែន ។

៥-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted]ពីបទ ហិង្សាដោយចេតនា(មានស្ថានទម្ងន់ទោស) តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ស្នើសុំមតុលាការ មេត្តាពិចារណាទៅតាមច្បាប់។ ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការអាចពិចារណាបាន ព្រោះបើតាមការ សារភាពរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងមន្ត្រីនគរបាលពិតជាមានលក្ខណ:ស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់ថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៦-យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយមន្ត្រីនគរបាល ក្នុងសំណុំរឿងមានលក្ខណ:ស៊ីសង្វាក់គ្នាយ៉ាងខ្លាំង អាចឲ្យតុលាការជឿបានថាជនជាប់ចោទឈ្មោ[redacted]ពិត ជាបានយកច្រវ៉ាក់វាយទៅលើឈ្មោ[redacted]ប្រាកដមែន ។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ [redacted]ភេទប្រុស អាយុ ១៩ ឆ្នាំ ។

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ ប្រព្រឹត្តនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុក បរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាម បញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៨-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ពុំទាមទារជម្ងឺចិត្តឡើយ គប្បីតុលាការមិនពិចារណា ។

៩-វត្ថុតាងរួមមានច្រវ៉ាក់ដែកចំនួនមួយខ្សែ ដែលជាវត្ថុតាងនៃបទល្មើស គប្បីតុលាការធ្វើការរឹបអូស និង បំផ្លាញចោល ។



Scanned by CamScanner

១០-ជនជាប់ចោទជានីតិជន ដែលមានភស្តុតាងឬសញ្ញាណបញ្ជាក់ថាកើតមានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបំពានច្បាប់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ:

ឈ្មោ[redacted]ភេទប្រុស អាយុ ១៩ ឆ្នាំ ជាប់ពន្ធនាគារ ២៤ (ម្ភៃបួន)ខែ ។

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ ប្រព្រឹត្តនៅភូមិកណ្តាល ឃុំត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុតាងមានច្រវ៉ាក់ចំនួនមួយខ្សែ តុលាការរឹបអូស និង បំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ប៉ាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner